**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ អង្គារ ១៣ រោច ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម លើកទី ៣

ព្រឹកថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម លើកទី ៣ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមលោកជំទាវជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីជំនាញមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធនានាដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈសំខាន់ៗ ដូចខាងក្រោម÷

**១. វឌ្ឍនភាពកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ ឆ្នាំ÷**

ក្រោយពីរាជរដ្ឋាភិបាល បានដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ ឆ្នាំ នៃគ្រួសារមានបណ្ណសមធម៌ ឬបណ្ណអាទិភាពកាលពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៩ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈទូទាំងប្រទេស កន្លងមក, គិតត្រឹមតំណាច់ខែ វិច្ឆិកា ឆ្នាំ ២០១៩, ស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ ឆ្នាំ បានមកទទួលសេវាពិនិត្យសុខភាពមានចំនួន ១៥២ ២៥៨ ករណី ក្នុងនោះ ស្ត្រីសម្រាលកូនមាន ចំនួន ២៣ ៧៩៤ ករណី ចំណែកឯស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ ឆ្នាំ ដែលបានមកពិនិត្យសុខភាពមុន និងក្រោយសម្រាលមានចំនួន ១២៨ ៤៦៤ ករណី ។

ដោយប្រើប្រាស់ថវិកាជាតិ, កម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ គ្របដណ្តប់ទៅលើស្ត្រីមានផ្ទៃពោះ នៃគ្រួសារមានបណ្ណសមធម៌ (IDPoor ១ និង IDPoor ២) និងបណ្ណអាទិភាព (Post ID) ហើយការអនុវត្តកម្មវិធីនេះ បានប្រព្រឹត្តទៅដោយរលូនតាមរយៈការប្រើបច្ចេកវិទ្យានៅលើតាប្លេត (Tablet) និងមានភ្នាក់ងារវេរប្រាក់ Wing ដែលជាដៃគូក្នុងការបើកផ្តល់ប្រាក់ដល់អ្នកទទួលផលដោយផ្ទាល់ ។ ជាទិសដៅបន្ត ក្រសួងសុខាភិបាល នឹងជំរុញការផ្សព្វផ្សាយបណ្តុះបណ្តាលបន្ថែមដល់មន្ត្រីនៅតាមមូលដ្ឋានសុខាភិបាលក្នុងការអនុវត្តកម្មវិធីនេះទៅតាមសមត្ថកិច្ច ក៏ដូចជាកិច្ចសហការ ដើម្បីរៀបចំប្រគល់កិច្ចការនេះជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដឹកនាំអនុវត្តបន្ត ទៅតាមកាលកំណត់ ។

**២. យន្តការ និងបទដ្ឋានគតិយុត្តនៃការផ្ទេរការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា÷**

ដើម្បីកាត់បន្ថយបន្ទុកកិច្ចការរដ្ឋបាលរបស់មន្ត្រីសុខាភិបាល និងអនុញ្ញាតឱ្យក្រសួងសុខាភិបាលផ្តោតការយកចិត្តទុកដាក់លើគុណភាពនៃការផ្តល់សេវាថែទាំ ក៏ដូចជា ផ្តល់ការព្យាបាលជូនប្រជាពលរដ្ឋកាន់តែប្រសើរ និងឈានទៅរៀបចំធ្វើសមាហរណកម្មកម្មវិធីជំនួយសង្គមផ្សេងទៀតទៅជាកម្មវិធីកញ្ចប់គ្រួសារ ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការផ្តល់ការឧបត្ថម្ភគាំទ្រដល់ពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ក៏ដូចជាដើម្បីពង្រឹងប្រសិទ្ធភាពនៃការចំណាយ

ថវិការដ្ឋ, រាជរដ្ឋាភិបាល បានសម្រេចផ្ទេរការដឹកនាំអនុវត្តកម្មវិធីឧត្តម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ ២ ឆ្នាំនេះ ពីក្រសួងសុខាភិបាល ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានប្រើប្រាស់យន្តការថ្នាក់ក្រោមជាតិ ។

កន្លងមក, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជាស្ថាប័នទទួលបន្ទុកដឹកនាំការងារនេះបន្ត បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍មួយចំនួន ដើម្បីរៀបចំយន្តការការងារដែលរួមមាន ការរៀបចំសៀវភៅប្រតិបត្តិគោល, ការផ្តល់ជូន Tablet ដល់មន្ត្រីទទួលបន្ទុកការងារនៅតាមឃុំ-សង្កាត់, និងការបណ្តុះបណ្តាលមន្ត្រីឃុំ-សង្កាត់ នៅទូទាំងប្រទេស ជាដើម ។

## ៣. វឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គម៖

ដើម្បីចូលរួមធានានូវសន្តិសុខប្រាក់ចំណូលរបស់មន្ត្រីសាធារណៈ និងដើម្បីរួមចំណែកកាត់បន្ថយគម្លាតរវាងនិវត្តជនចាស់ និងថ្មី, ក្នុងឆ្នាំ ២០១៩ នេះ, រាជរដ្ឋាភិបាល បានរ៉ាប់រងចំណាយទាំងស្រុង លើការឧបត្ថម្ភប្រាក់សោធនដោយរាជរដ្ឋាភិបាលបានវិភាជថវិកាចំនួន ៩២៦ ៦៧១ លាន រៀល ។ ក្នុងឆ្នាំ ២០១៩ នេះដែរ, រាជរដ្ឋាភិបាល ក៏បានវិភាជថវិកាចំនួន ៥០ ប៊ីលានរៀល ដើម្បីទ្រទ្រង់របបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលក្នុងនោះ គិតចាប់ពីខែមករា ដល់ខែតុលា ឆ្នាំ២០១៩, ប.ស.ស. បានទូទាត់ចំណាយចំនួន ៨១ ៦៧៧ ករណី ។

ជាមួយគ្នានេះ, ដើម្បីលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ រាជរដ្ឋាភិបាល ក៏បានផ្តល់ការថែទាំសុខភាពដោយឥតគិតថ្លៃតាមរយៈមូលនិធិសមធម៌សុខាភិបាលជូនគ្រួសារក្រីក្រ និងក្រុមពលរដ្ឋដ៏ទៃទៀត ដែលរួមមាន កម្មករក្រៅប្រព័ន្ធ អ្នកធាក់ស៊ីក្លូ កីឡាករជម្រើសជាតិ សមាជិកក្រុមប្រឹក្សាក្រុមប្រឹក្សាភូមិ-ឃុំ និងក្រុមគ្រួសារពលីមរណៈ ។ ក្នុងឆ្នាំ ២០១៩ នេះ, រាជរដ្ឋាភិបាល បានវិភាជថវិកាសរុបប្រមាណ ៨០ ប៊ីលានរៀល បូកបន្ថែមថវិការបស់ដៃគូអភិវឌ្ឍន៍ចំនួនប្រមាណ ៣៤ ប៊ីលានរៀល សម្រាប់អនុវត្តកម្មវិធីនេះ ។

ដោយឡែក សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន និយោជកជាអ្នករ៉ាប់រងទាំងស្រុងលើការបង់ភាគទានចូលក្នុងរបបថែទាំសុខភាព ដោយគិតចាប់ពីខែមករា ដល់ខែតុលា ឆ្នាំ២០១៩, ប.ស.ស. ប្រមូលវិភាគទាន និងបានចំណាយទូទាត់ទៅវិញសរុបចំនួន ២ ០៧៦ ៤១៦ ករណី ។ របបហានិភ័យការងារ ក៏ត្រូវទទួលបន្ទុកទាំងស្រុងដោយនិយោជក ផងដែរ ដែលគិតចាប់ពីខែមករា ដល់ខែតុលារ ឆ្នាំ២០១៩ នេះ ប.ស.ស ប្រមូលភាគទាន និងបានចំណាយទូទាត់វិញចំនួន ១៣ ៨៩៨ ករណី ។

## ៤. ផ្សេងៗ៖

អង្គប្រជុំ ក៏បានពិនិត្យ ផ្តល់យោបល់ និងសម្រេចលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មការជំនួយសង្គមរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម និងផែនការសកម្មភាពអទិភាពសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមសម្រាប់ឆ្នាំ ២០២០ ខាងមុខ ផងដែរ ។